# សុន្ទរកថា
## ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន
## និងជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ
## ក្នុងពិធីបើកសិក្ខាសាលាផ្សព្វផ្សាយលទ្ធផលសន្និសីទលើកទី២០ នៃបណ្តាភាគីអនុសញ្ញា
## ក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥

- *ឯកឧត្តម Jean-Claude Poimboeuf ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋបារាំងប្រចាំនៅកម្ពុជា*
- *ឯកឧត្តម លោកជំទាវ អនុប្រធាន សមាជិក សមាជិកា នៃគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ជាទីរាប់អាន*
- *ឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំ មន្ត្រីរាជការនៃក្រសួងបរិស្ថាន និងតំណាងដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងគ្រឹះស្ថានឧត្តមសិក្សា ទាំងអស់ជាទីមេត្រី*

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយ ដោយបានចូលរួមជាមួយឯកឧត្តម លោកជំទាវ លោក លោកស្រី ក្នុងពិធីបើកសិក្ខាសាលាផ្សព្វផ្សាយស្តីពីលទ្ធផលសន្និសីទលើកទី២០ នៃបណ្តាភាគីអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ នាពេលនេះ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមសម្តែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ដែលបានរៀបចំគោលយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាពនានាស្តីពីការប្រែប្រួលអាកាសធាតុ ជាពិសេស ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ។

ជាមួយគ្នានេះដែរ ខ្ញុំក៏សូមអរគុណយ៉ាងជ្រាលជ្រៅចំពោះនាយកដ្ឋានប្រែប្រួលអាកាសធាតុ ដែលបានខិតខំបំពេញភារកិច្ចរបស់ខ្លួន ក្នុងនាមលេខាធិការដ្ឋានរបស់គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ក្នុងការគាំទ្រដល់ការងារស្នូលរបស់គណៈកម្មាធិការលើការងារទំនាក់ទំនង សម្របសម្រួល និងគៀរគរថវិកាសម្រាប់ទ្រទ្រង់ដំណើរការការងារក្នុងរយៈកាលកន្លងមក។

ក្នុងនាមគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះការអញ្ជើញចូលរួមរបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី ក្នុងព្រឹត្តិការណ៍ដ៏មានសារៈសំខាន់នេះ ដើម្បីឆ្លុះបញ្ចាំងពីលទ្ធផលនៃកិច្ចពិភាក្សា ក្នុងសន្និសីទកំពូលលើកទី២០ នៅទីក្រុងលីម៉ានៃប្រទេសប៉េរូពាក់ព័ន្ធនឹងការដាក់ចេញនូវវិធានការ យន្តការ និងសេចក្តីសម្រេចចិត្តនានា។

ជាងនេះទៅទៀត ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះឯកឧត្តម *Jean-Claude* ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋបារាំង ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដែលបានថ្លែងសុន្ទរកថាគន្លឹះ ស្តីពីលទ្ធផលរំពឹងទុកនៃសន្និសីទលើកទី២១ នៃបណ្តាភាគីអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ដែលនឹងប្រព្រឹត្តទៅនៅទីក្រុងប៉ារីស នាចុងឆ្នាំ២០១៥នេះ។ ខ្ញុំសូមចូលរួមអបអរសាទរចំពោះរដ្ឋាភិបាល និងប្រជាជននៃសាធារណរដ្ឋបារាំង ដែលនឹងទទួលធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំសន្និសីទលើកទី២១ នេះ និងសូមឱ្យការងារនេះប្រព្រឹត្តទៅប្រកបដោយជោគជ័យ។

*អង្គសិក្ខាសាលាទាំងមូលជាទីមេត្រី!*

ដូចដែលឯកឧត្តម លោកជំទាវ លោក លោកស្រី បានជ្រាបស្រាប់ហើយថា ការប្រែប្រួលអាកាសធាតុ បានក្លាយជាបញ្ហាដ៏ចម្បង ដែលគម្រាមកំហែងយ៉ាងធ្ងន់ធ្ងរដល់ជីវភាពរស់នៅរបស់មនុស្សជាតិនៅទូទាំងពិភពលោក ជាពិសេសជីវភាពរបស់ប្រជាជននៃបណ្តាប្រទេសក្រីក្រ ដែលពឹងអាស្រ័យដោយផ្ទាល់លើធាតុអាកាស។ ការចរចាក្នុងរយៈកាលជាងម្ភៃឆ្នាំកន្លងមក ដើម្បីដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ នៅពុំទាន់សម្រេចបានលទ្ធផលជាដុំកំភួន សម្រាប់ធានាដល់ការផ្លាស់ប្តូរនិន្នាការប្រែប្រួលអាកាសធាតុជាសាកលនៅឡើយ។

ក្នុងនាមជាភាគីប្រទេសអភិវឌ្ឍន៍តិចតួច និងជាសមាជិកអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ កម្ពុជាចង់ឃើញមានការឯកភាពគ្នាជារួមលើកិច្ចព្រមព្រៀងអាកាសធាតុថ្មីមួយ ដែលជាលទ្ធផលនៃសន្និសីទលើកទី២១នាពេលខាងមុខ ហើយក៏ជាកិច្ចព្រមព្រៀង ដែលអនុលោមតាមគោលការណ៍ចម្បងៗរបស់អនុសញ្ញា ដែលគ្រប់ភាគីទាំងអស់អាចចូលរួមអនុវត្តបាន នៅឆ្នាំ២០២០។

ខ្ញុំមានជំនឿយ៉ាងមុតមាំថា ដើម្បីសម្រេចបាននូវកិច្ចព្រមព្រៀងទីក្រុងប៉ារីស នាពេលដ៏ខ្លីខាងមុខនេះ យើងចាំបាច់ត្រូវបន្តប្រមូលផ្តុំគំនិត និងបង្កើនកិច្ចពិភាក្សា ឆ្លើយតបនឹងសំណើរបស់បណ្តាប្រទេស ឬតំណាងក្រុមប្រទេស ដោយដាក់បញ្ចូលគំនិតទាំងនោះ ទៅក្នុងគ្រោងឆ្អឹងនៃកិច្ចព្រមព្រៀងអាកាសធាតុ សម្រាប់កិច្ចពិភាក្សារួម ដូចដែលភាគីទាំងអស់បានឯកភាព នៅក្នុងកិច្ចប្រជុំ នាទីក្រុងហ្សឺណែវ កាលពីខែកុម្ភៈ ឆ្នាំ២០១៥ កន្លងមកនេះ។

ក្នុងន័យនេះ ខ្ញុំយល់ថា គ្រប់ភាគីពាក់ព័ន្ធគួរគិតគូរដល់ប្រយោជន៍រួម ដោយត្រូវសំយោគគំនិតសំខាន់ៗរបស់ បណ្តាប្រទេសភាគី តាមរយៈរបាយការណ៍ស្តីពីការកំណត់ការរួមចំណែកថ្នាក់ជាតិ ដែលផ្តោតជាសំខាន់លើបញ្ហាការបាត់បង់ និងការខូចខាត បញ្ហាសុខភាព ហិរញ្ញប្បទានអាកាសធាតុ ការផ្ទេរបច្ចេកវិទ្យា និងនីតិវិធីសម្រួលឯកសារកិច្ចព្រមព្រៀង ដើម្បីជាមូលដ្ឋាន ក្នុងការពិភាក្សានិងការចរចា។

ជារួម កម្ពុជាចង់ឱ្យបណ្តាប្រទេសឧស្សាហកម្មជឿនលឿនបង្កើនតួនាទីនាំមុខគេក្នុងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ហើយប្រទេសទាំងនេះ ក៏ត្រូវបង្កើនការគាំទ្រដល់បណ្តាប្រទេសកំពុងអភិវឌ្ឍនូវហិរញ្ញប្បទាន ការផ្ទេរបច្ចេកវិទ្យាសមស្រប ការកសាងសមត្ថភាព សម្រាប់ជាមធ្យោបាយឆ្លើយតបនឹងបញ្ហាប្រែប្រួលអាកាសធាតុ។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី!*

ថ្វីត្បិតតែ គោលដៅអាទិភាពសម្រាប់ការអភិវឌ្ឍនៅកម្ពុជានៅមានច្រើនបើប្រៀបធៀបនឹងប្រទេសជឿនលឿន ហើយធនធានមនុស្ស និងសម្ភារ ក៏ដូចជា បច្ចេកវិទ្យានៅមានកម្រិត ក៏រាជរដ្ឋាភិបាលកម្ពុជាមានឆន្ទៈនយោបាយខ្ពស់ ក្នុងការត្រៀមខ្លួនចូលរួមដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ ដោយផ្អែកលើគោលការណ៍អនុសញ្ញាប្រែប្រួលអាកាសធាតុ។

ជាក់ស្តែង ដើម្បីបញ្ជាក់នូវជំហរនិងការប្តេជ្ញាចិត្តក្នុងការចូលរួមជាមួយសហគមន៍អន្តរជាតិ ក្នុងការដោះស្រាយបញ្ហានេះ កម្ពុជាបាននិងកំពុងរៀបចំបែបបទ ដើម្បីចុះហត្ថលេខាទទួលស្គាល់វិសោធនកម្មទីក្រុងដូហាស្តីពីកាតព្វកិច្ចលើកទី២ នៃពិធីសារក្យូតូ ស្របតាមសេចក្តីសម្រេចរបស់សន្និសីទបណ្តាភាគីជាសមាជិកអនុសញ្ញាប្រែប្រួលអាកាសធាតុ។

នៅចំពោះមុខ យើងបានដាក់ឱ្យប្រើប្រាស់ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣ ហើយក៏បាននិងកំពុងអនុវត្តនូវការងារអាទិភាពមួយចំនួន រួមមាន៖ ការបញ្ជ្រាបការងារប្រែប្រួលអាកាសធាតុទៅក្នុងវិស័យពាក់ព័ន្ធ ការរៀបចំយន្តការហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ និងក្របខ័ណ្ឌអង្កេតតាមដាន ការកៀរគរធនធាន ការអនុវត្តគម្រោងសាកល្បងសម្រាប់បន្សាំនិងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ការកសាងសមត្ថភាពស្ថាប័ននិងសមត្ថភាពបច្ចេកទេស ការសិក្សាស្រាវជ្រាវ អប់រំនិងលើកកម្ពស់ការយល់ដឹង និងការពង្រឹងតួនាទីវិស័យឯកជន។ល។

ជាងនេះទៅទៀត កម្ពុជាបានរៀបចំរបាយការណ៍ស្តីការកំណត់ការរួមចំណែកថ្នាក់ជាតិ (Intended Nationally Determined Contributions: INDCs) សម្រាប់ដាក់ជូនលេខាធិការដ្ឋាននៃអនុសញ្ញាឱ្យបានមុនសន្និសីទលើកទី២១ នៅទីក្រុងប៉ារីស។ របាយការណ៍នេះ នឹងត្រូវបានគិតគូរឱ្យបានកាន់តែទូលំទូលាយ បន្ថែមលើគោលដៅនៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ពោលគឺយើងនឹងដាក់បញ្ចូលព័ត៌មានពាក់ព័ន្ធនឹងគ្រប់ធាតុចូលទាំងអស់ រួមមាន តម្រូវការហិរញ្ញប្បទាន ជម្រើសនិងសកម្មភាពបន្សាំចាំបាច់នានា តម្រូវការបច្ចេកវិទ្យា និងការកសាងសមត្ថភាព។ល។

ក្នុងនាមគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ និងក្នុងនាមក្រសួងបរិស្ថាន ខ្ញុំសូមអំពាវនាវដល់គ្រប់ក្រសួង ស្ថាប័ន អាជ្ញាធរដែនដី អង្គការមិនមែនរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន បន្តជួយឧបត្ថម្ភ គាំទ្រ និងចូលរួមគ្រប់សកម្មភាពអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម សំដៅធានាឱ្យបាននូវប្រសិទ្ធភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុកម្ពុជា។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណចំពោះវត្តមានរបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលនឹងញ៉ាំងឱ្យកម្មវិធីថ្ងៃនេះនឹងប្រព្រឹត្តទៅ សម្រេចបានជោគជ័យ តាមការគ្រោងទុក។ តាមរយៈសិក្ខាសាលាថ្ងៃនេះ យើងនឹងបានយល់កាន់តែច្បាស់អំពីលទ្ធផល និងការវិវត្តថ្មីៗនៃការចរចាបង្កើតកិច្ចព្រមព្រៀងអាកាសធាតុថ្មី។

ដើម្បីធានាបាននូវគោលបំណងរួមរបស់សិក្ខាសាលា ខ្ញុំសូមជំរុញឱ្យឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិក សមាជិកា នៃអង្គសិក្ខាសាលាទាំងអស់ ខិតខំយកចិត្តទុកដាក់ចូលរួមផ្លាស់ប្តូរមតិយោបល់ សំដៅរួមចំណែកដល់ជំហររបស់រាជរដ្ឋាភិបាល សម្រាប់កិច្ចចរចានាពេលខាងមុខ។

ជាទីបញ្ចប់ ខ្ញុំសូមគោរពជូនពរ សូមប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុៈ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងសូមមានសុភមង្គលគ្រប់ក្រុមគ្រួសារ។

**ខ្ញុំសូមប្រកាសបើកអង្គសិក្ខាសាលាចាប់ពីពេលនេះតទៅ៕**

*សូមអរគុណ!*